**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Royal University of Law and Economics

# កិច្ចការស្រាវជ្រាវ

# ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅ ប្រព័ន្ធតុលាការ

រៀបចំដោយនិស្សិតក្រុម៤ឈ្មោះ ៖

១. ជឹម វិច្ឆ៉ា
២. បេអ៊ុយ លីហ្សា
៣. ម៉ម ច័ន្ទមល្លិកា
៤. វ៉ាង ផល្លី
៥. ជីវិន ជីវ៉ា
៦. វ៉ែន សំអាន

មុខវិជ្ជា : **វិធីសាស្ត្រស្រាវជ្រាវ**

បង្រៀនដោយសាស្ត្រាចារ្យ ៖ **បណ្ឌិត ព្រុំ ទេវី**

ថ្នាក់: L2B01

**ឆ្នាំសិក្សា ២០២៥-២០២៦**

## កិច្ចការស្រាវជ្រាវ

### ១. ប្រធានបទ

ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ។

### ២. ចំណោទបញ្ហា

តើការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការមានន័យដូចម្ដេច?

### ៣. បញ្ហាបន្ទាប់បន្សំ

1. តើការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ ក្នុងប្រទេសកម្ពុជាអាចប្រព្រឹត្តទៅបានផ្អែកតាមយន្តការណាខ្លះ?
2. តើមាននីតិវិធីដូចម្ដេចអ្វីខ្លះក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ?
3. តើដំណាក់កាលនានានៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការមានដូចម្ដេចខ្លះ ?

### ៤. គោលដៅនៃការសិក្សាស្រាវជ្រាវ

1. សិក្សាអំពីយន្តការនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ ក្នុងប្រទេសកម្ពុជា។
2. សិក្សាអំពីនីតិវិធីក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
3. សិក្សាអំពីដំណាក់កាលនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ។

### ៥. សម្មតិកម្ម និងអថេរ

### សម្មតិកម្មខាយ

ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ (ដូចជា អាជ្ញាកណ្ដាល) នោះវិវាទនឹងត្រូវបានបញ្ចប់បានឆាប់រហ័ស ។

**អថេរ**

អថេរមិនអាស្រ័យ : ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ឧ. អាជ្ញាកណ្ដាល សម្រុះសម្រួល)។

អថេរអាស្រ័យ : វិវាទបានបញ្ចប់ដោយឆាប់រហ័ស និងមានប្រសិទ្ធភាព

### សម្មតិកម្មស្មុគស្មាញ

ដោយជ្រើសរើសការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រួមជាមួយកម្រិតនៃការសហការរបស់ភាគីមានភាពល្អប្រសើរ និងបទពិសោធន៍ខ្ពស់របស់អាជ្ញាកណ្ដាល ទោះបីស្ថានភាពទីផ្សារសំណង់ស្ថិតនៅស្ថិរភាព ឬមានផលប៉ះពាល់តិច ក៏វិវាទនឹងត្រូវបានបញ្ចប់ឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់ ។

**អថេរ**

អថេរអន្តរាគមន៍ : ការសហការរបស់ភាគី និងបទពិសោធន៍របស់អាជ្ញាកណ្ដាល

អថេរខាងក្រៅ: ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ៦. ដែននៃការស្រាវជ្រាវ

នៅឆ្នាំ២០២០ នៅប្រទេសកម្ពុជា បានពង្រឹងយន្តការដោះស្រាយវិវាទក្រៅតុលាការ ដូចជា ការចរចា ការសម្រុះសម្រួល និងអាជ្ញាកណ្ដាល ឲ្យមានភាពរហ័ស តម្លៃសមរម្យ និងមានប្រសិទ្ធភាព។ វិធីសាស្ត្រទាំងនេះជួយឲ្យភាគីអាចដោះស្រាយបញ្ហាបានដោយសន្តិវិធី និងរក្សាទំនាក់ទំនងអាជីវកម្មបានល្អ។

## ៧. ដែនកំណត់

កំណត់គោលដៅសម្រាប់ប្រមូលទិន្នន័យ៖

ទិន្នន័យដែលមានស្រាប់៖

- ឯកសសារនៅ E-Library នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- តាមរយៈប្រព័ន្ធផ្សព្វផ្សាយ(google)
- ក្រសួងយុត្តិធម៌
- របាយការណ៍ និងសេចក្ដីសម្រេចអាជ្ញាកណ្ដាល

ទិន្នន័យបឋម៖

- សម្ភាសន៍នៅក្រសួងយុត្តិធម៌
- មជ្ឈមណ្ឌលអាជ្ញាកណ្ដាល ឬស្ថាប័នពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ក្រុមហ៊ុន ឬសហគ្រាសដែលធ្លាប់ប្រើវិធីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
  ក្រុមគោលដៅសម្រាប់ប្រមូលទិន្នន័យបឋម៖
- ចៅក្រម និងព្រះរាជអាជ្ញា (ពាក់ព័ន្ធនឹងការទទួលស្គាល់សេចក្ដីសម្រេចអាជ្ញា កណ្ដាល)
- អាជ្ញាកណ្ដាល និងមេធាវីផ្នែកពាណិជ្ជកម្ម

- សាស្ត្រាចារ្យផ្នែកច្បាប់ពាណិជ្ជកម្ម
- អាជីវករ ឬភាគីដែលធ្លាប់ចូលរួមក្នុងការចរចា សម្របសម្រួល ឬអាជ្ញាកណ្តាល

# អារម្ភកថា

ជាកិច្ចចាប់ផ្ដើមយើងខ្ញុំគោរពជម្រាបសួរ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ព្រមទាំងអ្នកសិក្សាស្រាវជ្រាវទាំងអស់គ្រប់មជ្ឈដ្ឋានជាទីគោរព។

យើងខ្ញុំទាំងអស់គ្នា ជាក្រុមនិស្សិតឆ្នាំទី២ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទមួយទាក់ទងទៅនឹង "ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅព័ន្ធតុលាការ"។

ក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការធ្វើប្រតិបត្តិការពាណិជ្ជកម្មរវាងបុគ្គល ឬអង្គភាពផ្សេងៗ កាន់តែមានការកើនឡើង។ ជាទូទៅ វិវាទពាណិជ្ជកម្មអាចត្រូវបានដោះស្រាយតាមរយៈប្រព័ន្ធតុលាការ ប៉ុន្តែដំណើរការនេះអាចចំណាយពេលយូរ ចំណាយថវិកាច្រើន និងអាចប៉ះពាល់ដល់ទំនាក់ទំនងពាណិជ្ជកម្មរវាងភាគី។ ដូច្នេះ ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ បានក្លាយជាជម្រើសដ៏សំខាន់មួយដែលជួយដោះស្រាយវិវាទបានយ៉ាងមានប្រសិទ្ធភាព រហ័ស និងបត់បែន។

ហេតុនេះហើយ ការស្រាវជ្រាវអំពី "ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ" នឹងជួយបង្កើនការយល់ដឹងរបស់សិស្សអំពីសារសំខាន់និងប្រសិទ្ធភាពនៃវិធីសាស្ត្រយវិវាទពាណិជ្ជកម្ម។ ការស្រាវជ្រាវនេះក៏មានបំណងបង្ហាញពីកត្តាផ្សេងៗដែលអាចជួយឱ្យដំណើរការដោះស្រាយវិវាទមានប្រសិទ្ធភាព និងរួមចំណែកក្នុងការលើកកម្ពស់បរិយាកាសពាណិជ្ជកម្មនៅកម្ពុជា។

យ៉ាងណាមិញ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំក៏សូមខន្តីអភ័យទោសសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកសិក្សាទាំងឡាយនូវកំហុសដែលកើតឡើងដោយអចេតនាក្នុងសៀវភៅនេះ ទាំងអក្ខរាវិរុទ្ធ និងខ្លឹមសារនៃការស្រាវជ្រាវ។ ប្រសិនបើមានកំហុសឆ្គងត្រង់ចំណុចណាមួយក្នុងសៀវភៅនេះ ក្រុមយើងខ្ញុំក៏សូមអធ្យាស្រ័យពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តអ្នកអាន និងអ្នកសិក្សាទាំងអស់ដោយក្ដីអនុគ្រោះ។

# សេចក្តីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២៥-២០២៦សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

អ្នកមានគុណទាំងពីររូបនោះគឺមាតាបិតា ដែលជាទីគោរពស្រឡាញ់របស់យើងខ្ញុំទាំងអស់គ្នា និងជាអ្នកមានគុណដ៏ធំធេងដែលមិនអាចកាត់ថ្លៃបាន។ កូនសូមសម្តែងការគោរពដឹងគុណចំពោះ លោកឪពុក អ្នកម្តាយ ដែលបានខិតខំប្រឹងប្រែងតស៊ូធ្វើការចិញ្ចឹមបីបាច់ថែរក្សាកូន តាំងពីកុមារភាព រហូតបានធំពេញវ័យ និងបានផ្តល់ការសិក្សារៀនសូត្រ ជួយទំនុកបម្រុងគ្រប់បែបយ៉ាងដល់កូន លើកទឹកចិត្តកូន ព្រមទាំងអប់រំទូន្មានកូនក្នុងគោលបំណងឱ្យកូនក្លាយជាធនធានមនុស្សល្អម្នាក់ក្នុងសង្គម។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកគ្រូ ព្រុំ ទេវី ក្នុងការណែនាំតម្រង់ទិសឱ្យយើងខ្ញុំទាំងអស់គ្នាបានយល់កាន់តែស៊ីជម្រៅលើមុខវិជ្ជា វិធីសាស្ត្រស្រាវជ្រាវ និងបានយកចិត្តទុកដាក់ក្នុងការពន្យល់ ណែនាំ ផ្តល់ដំបូន្មានល្អៗ ផ្តល់វិធីសាស្ត្រក្នុងការស្រាវជ្រាវផ្សេងៗ។

ជាចុងបញ្ចប់ក្រុមយើងខ្ញុំសូមលើកដៃបួងសួងដល់វត្ថុសក្តិសិទ្ធទាំងអស់ សូមឱ្យថែរក្សានូវលោកទាំងឡាយជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## មាតិកា


**សេចក្តីផ្តើម**

**ជំពូកទី១ ទ្រឹស្តីទូទៅអំពីការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ** ........ 2

១.១ និយមន័យនៃវិវាទពាណិជ្ជកម្ម ........ 2

១.២ និយមន័យនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ 2

១.១.១ គោលគំនិតនៃការដោះស្រាយវិវាទក្រៅតុលាការ ........ 2

១.១.២ លក្ខណៈពិសេសនៃការដោះស្រាយវិវាទក្រៅតុលាការ ........ 2

១.៣ អត្ថប្រយោជន៍នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ 3

១.៤ គុណវិបត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ 3

**ជំពូកទី២ យន្តការនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជា** ........ 4

២.១ ការចរចារ ........ 4

២.១.១ និយមន័យនៃការចរចា ........ 4

២.១.២ លក្ខណៈនៃការចរចារ ........ 4

២.២ ការសម្រុះសម្រួល ........ 5

២.៣ តួនាទី និងសិទ្ធរបស់អាជ្ញាកណ្តាល ........ 5

២.៤ ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅតុលាការ ........ 6

២.៤.១ ច្បាប់ស្តីពីអាជ្ញាកណ្តាលពាណិជ្ជកកម្ម ........ 6

**ជំពូកទី៣ នីតិវិធីនិងដំណាក់កាលនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ** ........ 7

៣.១ នីតិវិធីនៃការដោះស្រាយវិវាទក្រៅតុលាការ .......... 7
៣.១.១ ការដាក់ពាក្យស្នើរសុំដោះស្រាយវិវាទ .......... 7
៣.១.២ ការជ្រើសរើសអ្នកសម្រុះសម្រួល ឬអាជ្ញាកណ្តាល .......... 8
៣.២ ដំណាក់កាលនៃការដោះស្រាយវិវាទ .......... 8
៣.៣ កត្តាដដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទ .......... 9
៣.៣.១ ការសហការរបស់ភាគី .......... 9
៣.៣.២ បទពិសោធន៍របស់អាជ្ញាកណ្តាល .......... 9
៣.៣.៣ កត្តាច្បាប់និងស្ថានភាពទីផ្សារ .......... 9
**សេចក្តីសន្និដ្ឋាន**
**ឯកសារយោង**

# សេចក្តីផ្តើម

នៅក្នុងសម័យបច្ចុប្បន្ន ការរីកចម្រើននៃសេដ្ឋកិច្ច និងការពង្រីកសកម្មភាពពាណិជ្ជកម្ម បានធ្វើឱ្យមានការកើនឡើងនៃទំនាក់ទំនងពាណិជ្ជកម្មរវាងបុគ្គល សហគ្រាស និងអង្គភាពផ្សេងៗ។ ជាមួយនឹងការកើនឡើងនៃសកម្មភាពទាំងនេះ ក៏អាចបង្កឱ្យមានវិវាទពាណិជ្ជកម្មកើតឡើងផងដែរ។ វិវាទអាចកើតឡើងដោយសារការមិនយល់ស្របលើលក្ខខណ្ឌនៃកិច្ចសន្យា ការបកស្រាយខុសគ្នា ឬការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីណាមួយ។ ប្រសិនបើវិវាទទាំងនេះមិនត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវ វាអាចប៉ះពាល់ដល់ទំនាក់ទំនងពាណិជ្ជកម្ម និងស្ថិរភាពនៃសកម្មភាពសេដ្ឋកិច្ច។ វិវាទពាណិជ្ជកម្មអាចត្រូវបានដោះស្រាយតាមរយៈប្រព័ន្ធតុលាការ។ ទោះជាយ៉ាងណាក៏ដោយការដោះស្រាយតាមតុលាការមួយចំនួនអាចចំណាយពេលយូរ ចំណាយថវិកាច្រើន និងអាចបង្កឱ្យមានភាពតានតឹងរវាងភាគីទាំងពីរ។ ដោយសារហេតុនេះ ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ បានក្លាយជាវិធីសាស្ត្រសំខាន់មួយសម្រាប់ជួយដោះស្រាយវិវាទបានយ៉ាងមានប្រសិទ្ធភាព និងឆាប់រហ័ស។

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រដែលអនុញ្ញាតឱ្យភាគីដែលមានវិវាទអាចស្វែងរកដំណោះស្រាយដោយការពិភាក្សា ឬតាមរយៈជំនួយពីភាគីទីបី ដោយមិនចាំបាច់បញ្ជូនករណីទៅតុលាការ។ វិធីសាស្ត្រនេះរួមមាន ការចរចា ការសម្របសម្រួល និងអាជ្ញាកណ្តាល ដែលអាចជួយឱ្យភាគីពាក់ព័ន្ធរកដំណោះស្រាយដោយសន្តិវិធី និងរក្សាទំនាក់ទំនងពាណិជ្ជកម្មរវាងគ្នា។

ដោយសារសារៈសំខាន់នៃវិធីសាស្ត្រនេះការសិក្សាអំពីការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ មានគោលបំណងបង្ហាញពីគោលការណ៍ និងសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្រនេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម។ ការស្រាវជ្រាវនេះក៏មានគោលបំណងជួយឱ្យយល់ដឹងកាន់តែច្បាស់អំពីតួនាទីនិងអត្ថប្រយោជន៍នៃការដោយស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងការលើកកម្ពស់បរិយាកាសពាណិជ្ជកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច។

# ជំពូកទី១ ទ្រឹស្តីទូទៅអំពីការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ

## ១.១. និយមន័យនៃវិវាទពាណិជ្ជកម្ម

វិវាទពាណិជ្ជកម្ម គឺជាការខ្វែងគំនិត ឬជម្លោះដែលកើតឡើងរវាងភាគីពីរ ឬច្រើន ដែលពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្ម ដូចជា ការទិញលក់ទំនិញ កិច្ចសន្យាអាជីវកម្ម ការផ្តល់សេវាកម្ម ឬការវិនិយោគ។ ជម្លោះនេះកើតឡើងនៅពេលដែលភាគីមួយមិនគោរព ឬអនុវត្តមិនត្រឹមត្រូវតាមកិច្ចសន្យា ឬកាតព្វកិច្ចដែលបានព្រមព្រៀងគ្នា។ ឧទាហរណ៍វិវាទពាណិជ្ជកម្ម៖ ជម្លោះអំពី ការមិនបង់ប្រាក់ តាមកិច្ចសន្យា ជម្លោះអំពី គុណភាពទំនិញ ឬសេវាកម្ម ជម្លោះអំពី ការបំពានកិច្ចសន្យា ជម្លោះរវាង ក្រុមហ៊ុន និងដៃគូអាជីវកម្ម។

## ១.២. និយមន័យនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានន័យថា ការដោះស្រាយជម្លោះ ឬវិវាទរវាងភាគីពីរ ឬច្រើន ដោយមិនចាំបាច់យកករណីទៅដោះស្រាយនៅតុលាការ ប៉ុន្តែប្រើវិធីផ្សេងៗដូចជា ការចរចា ការសម្រុះសម្រួល ឬអាជ្ញាកណ្តាល ដើម្បីរកដំណោះស្រាយដែលទាំងអស់គ្នាអាចទទួលយកបាន។

### ១.១.១. គោលគំនិតនៃការដោះស្រាយវិវាទក្រៅតុលាការ

គោលគំនិតនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាគំនិតក្នុងការដោះស្រាយជម្លោះរវាងភាគី ដោយប្រើវិធីសាស្ត្រផ្សេងៗក្រៅពីការប្តឹងទៅតុលាការ។ វាមានគោលបំណងធ្វើឱ្យការដោះស្រាយវិវាទមានភាពលឿន ប្រសិទ្ធភាព កាត់បន្ថយការចំណាយ និងរក្សាទំនាក់ទំនងល្អរវាងភាគីដែលពាក់ព័ន្ធ។

### ១.១.២. លក្ខណៈពិសេសនៃការដោះស្រាយវិវាទក្រៅតុលាការ

លក្ខណៈពិសេសនៃការដោះស្រាយវិវាទក្រៅតុលាការ ធ្វើក្រៅប្រព័ន្ធតុលាការ ការដោះស្រាយវិវាទមិនត្រូវការយកករណីទៅប្តឹង ឬកាត់ក្តីនៅតុលាការ។ នីតិវិធីសាមញ្ញ និងបត់បែន វិធីសាស្ត្រដោះស្រាយមានភាពងាយស្រួល និងមិនស្មុគស្មាញដូចនីតិវិធីតុលាការ សន្សំសំចៃពេលវេលា ដំណើរការដោះស្រាយអាចបញ្ចប់បានលឿនជាងការកាត់ក្តីនៅតុលាការ កាត់បន្ថយការចំណាយ ចំណាយលើការដោះស្រាយវិវាទតិចជាងការដោះស្រាយតាមផ្លូវតុលាការ រក្សាការសម្ងាត់ ការដោះស្រាយភាគច្រើនធ្វើដោយសម្ងាត់ មិនបង្ហាញជាសាធារណៈ រក្សាទំនាក់ទំនងរវាងភាគី ជួយឱ្យភាគីនៅតែអាចបន្តទំនាក់ទំនងល្អ ជាពិសេសក្នុងអាជីវកម្ម។

## ១.៣. អត្ថប្រយោជន៍នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រដោះស្រាយវិវាទដែលមិនចាំបាច់ដាក់បណ្តឹងទៅតុលាការ ដូចជា ការចរចា ការសម្របសម្រួល និងអាជ្ញាកណ្តាល។ វិធីសាស្ត្រនេះមានអត្ថប្រយោជន៍ដូចជា ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការមានការចំណាយថវិកាតិចជាងការដាក់បណ្តឹងទៅតុលាការ អាចដោះស្រាយវិវាទបានលឿនជាងនីតិវិធីតុលាការ ដែលភាគច្រើនចំណាយពេលយូរ។ រក្សាទំនាក់ទំនងអាជីវកម្ម ភាគីទាំងពីរអាចរកដំណោះស្រាយដោយសន្តិវិធី ដូច្នេះអាចបន្តទំនាក់ទំនងពាណិជ្ជកម្មបាន ហើយអាចរក្សាទំនាក់ទំនងល្អរវាងគ្នា និងគ្នាហើយបញ្ចប់វិវាទដោយសន្តិវិធី មានភាពសម្ងាត់ ការដោះស្រាយជាច្រើនត្រូវធ្វើដោយសម្ងាត់ មិនប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ភាគី ភាគីអាចព្រមព្រៀងលើនីតិវិធី និងដំណោះស្រាយដែលសមស្របជាមួយស្ថានភាពរបស់ខ្លួន។ ការដោះស្រាយវិវាទក្រៅ ប្រព័ន្ធតុលាការ អាចធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ ក្នុងសង្គមតាមរយៈការព្យាយាម សម្រុះសម្រួល ផ្សះផ្សារបញ្ចប់វិវាទក្រៅប្រព័ន្ធតុលាការ និងជួយកាត់បន្ថយការ កកស្ទះសំណុំរឿង នៅតាមមូលដ្ឋានផងដែរ ហើយក៏បាន ជួយបង្កិត សេវាដោះស្រាយវិវាទឱ្យកាន់តែកៀកនឹងប្រជាពលរដ្ឋក្នុងមូលដ្ឋានផងដែរ ។

## ១.៤. គុណវិបត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

អំណាចបង្ខំអនុវត្តមានកម្រិតប្រសិនបើភាគីមួយមិនគោរពកិច្ចព្រមព្រៀងអាចត្រូវតែទៅតុលាការវិញ។ មិនមានស្តង់ដារតែមួយ នីតិវិធីអាចខុសគ្នាតាមករណី ឬតាមអ្នកដោះស្រាយវិវាទ អាចមានភាពលំអៀង ប្រសិនបើអ្នកសម្របសម្រួល ឬអាជ្ញាកណ្តាលមិនមានភាពអព្យាក្រឹត មិនសមស្របសម្រាប់វិវាទធ្ងន់ធ្ងរ វិវាទខ្លះដែលពាក់ព័ន្ធនឹងច្បាប់សំខាន់ ឬផលប៉ះពាល់ធំៗ ត្រូវការការសម្រេចពីតុលាការ។

# ជំពូកទី២ យន្តការនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជា

## ២.១. ការចរចារ

### ២.១.១. និយមន័យនៃការចរចា

ការចរចាជាវិធីដោះស្រាយមួយដែលមានលក្ខណៈដំបូងគេដោយភាគីទាំងឡាយ ឬតំណាងរបស់គេប្រើការអន្ទង និងការធ្វើសម្បទានដើម្បីដោះស្រាយវិវាទដោយផ្ទាល់រវាងពួកគេដោយគ្មានជំនួយពីតតីយជនឡើយ។[1] ការចរចាជាដំណើរការមួយដែលភាគីពាក់ព័ន្ធក្នុងវិវាទ បានព្យាយាមដោះស្រាយបញ្ហាដោយការពិភាក្សាផ្ទាល់ រវាងពួកគេ។

### ២.១.២. លក្ខណៈនៃការចរចារ

ការចរចាជានីតិវិធីមួយដែលមានលក្ខណៈងាយស្រួល និងសាមញ្ញដែលត្រូវបានប្រើប្រាស់ជារៀង រាល់ថ្ងៃក្នុងជីវភាពរស់នៅ និងក្នុងការដោះស្រាយវិវាទផ្សេងៗផងដែរ ទោះបីនៅក្នុងប្រព័ន្ធច្បាប់ទាំងពីររបស់ ពិភពលោកដូចជាប្រព័ន្ធច្បាប់ស៊ីវិល ឬប្រព័ន្ធច្បាប់អង់គ្លេសក៏ដោយ។ ការចចារកើតឡើងនៅពេលដែលគូភាគីនៃជម្លោះ ព្យាយាមដោះស្រាយនូវជម្លោះរបស់ពួកគេដោយខ្លួន ឯងផ្ទាល់ ឬតាមរយៈអ្នកតំណាងរបស់ពួកគេ[2] ហើយការចចារគឺជាវិធីដោះស្រាយជម្លោះតាមផ្លូវច្បាប់តែមួយ គត់ដែលមិនមានភាគីអព្យាក្រឹត្យចូលរួម។ ការចរចាអាចធ្វើឡើងតាមវិធីជាច្រើនយ៉ាងផ្សេងៗគ្នាដូចជាដោយ ផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ។ ការចរចាអាចធ្វើឡើងតាមបែបធម្មតា ឬលក្ខណៈផ្លូវការ។ គេក៏អាចធ្វើការ ចរចាតាមរយៈសំបុត្រ ឬអ៊ីមែលផងដែរ។ នៅក្នុងប្រទេសកម្ពុជាការចរចាជាច្រើនតែងធ្វើឡើងនៅចំពោះមុខគ្នាផ្ទាល់ ប៉ុន្តែគេក៏អាចចរចាតាមទូរស័ព្ទផងដែរ។ ច្បាប់របស់ប្រទេសកម្ពុជាគាំទ្រឲ្យមានការការចរចា ព្រោះការចរចាមាន ហេតុផលវិជ្ជមានជាច្រើនសម្រាប់គូភាគីជម្លោះ។ ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាក៏បានលើកទឹកចិត្ត ឲ្យមានការស្រុះស្រួលគ្នាតាមការចរចារបស់គូភាគីវិវាទទាំងពីរផងដែរ។[3] លើសពីនេះទៅទៀតការចរចាអាចជួយ ឲ្យគូភាគីរក្សាបាននូវទំនាក់ទំនងល្អព្រោះការចរចាតម្រូវឲ្យគូភាគីវិវាទសហការគ្នាឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យមាន កិច្ចព្រមព្រៀងរបស់គូភាគី។

[1] កៅ សីហា, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឆ្នាំ២០១០ ទំព័រ២។

[2] សៀវភៅរបស់មូលនិធិអាស៊ីស្តីពីដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ បោះពុម្ពឆ្នាំ២០០១ ទំព័រ៦។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦,មាត្រា៩៧។

## ២.២. ការសម្រុះសម្រួល

ការសម្រុះសម្រួល ឬសន្ធានកម្ម និងពាក្យថាការផ្សះផ្សាត្រូវបានប្រើលាយឡំគ្នាអស់រយៈពេលជាច្រើនឆ្នាំមកហើយពីសំណាក់មជ្ឈដ្ឋានអ្នកសិក្សា ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងតុលាការ។ សព្វថ្ងៃនេះពាក្យថាសន្ធានកម្ម និងការផ្សះផ្សា ជាញឹកញាប់ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកដើម្បីសំដៅដល់ដំណើរការតែមួយ។ ជាទូទៅសន្ធានកម្ម ឬការផ្សះផ្សាសំដៅដល់ការដោះស្រាយជម្លោះ ដោយមានជំនួយពីភាគីទីបី ដែលដាក់ឲ្យអនុវត្តវិធានជាមូលដ្ឋានមួយស្នើជូនមតិ និងស្នើឡើងនូវដំណោះស្រាយ ក៏ប៉ុន្តែមិនរហូតដល់ធ្វើសេចក្តីសម្រេចពីជម្លោះនោះទេ វាគឺជាការបន្តដំណើរការចរចាដែលនៅក្នុងនោះភាគីទីបី ដឹកនាំភាគីវិវាទឲ្យជួបគ្នាដើម្បីដោះស្រាយបញ្ហា[4] ជាទូទៅសន្ធានកម្មកើតឡើងបន្ទាប់ពីភាគីទាំងឡាយព្យាយាមចរចារវាងពួកគេ ប៉ុន្តែមិនអាចសម្រេចរកដំណោះស្រាយណាមួយបាន។ ដូចនេះសន្ធានកម្ម ឬការផ្សះផ្សានៅក្នុង វិវាទត្រូវតែមានការចូលរួមពីភាគីទីបីដែលជាអ្នកសម្រុះសម្រួល។[5]

## ២.៣. តួនាទី និងសិទ្ធរបស់អាជ្ញាកណ្តាល

នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ពាក្យថា "អាជ្ញាកណ្តាល" ជាទូទៅសំដៅលើ មជ្ឈត្តករ ដែលដើរតួនាទីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬអាចសំដៅដល់ ព្រះរាជអាជ្ញាក្នុងន័យជាភ្នាក់ងាររដ្ឋអមតុលាការ។ ខាងក្រោមនេះគឺជាតួនាទី និងសិទ្ធិរបស់ពួកគេ៖

**ក. មជ្ឈត្តករ (អាជ្ញាកណ្តាលក្នុងវិវាទកម្ម)៖** មជ្ឈត្តករគឺជាបុគ្គលដែលភាគីវិវាទជ្រើសរើស ដើម្បីសម្រេចសេចក្តីលើជម្លោះ (ជាពិសេសវិវាទពាណិជ្ជកម្ម ឬការងារ) ដោយមិនឆ្លងកាត់តុលាការរដ្ឋ។ មានតួនាទី ពិនិត្យអង្គហេតុ និងភស្តុតាងដែលភាគីទាំងសងខាងដាក់ជូន។ សម្របសម្រួល និងធ្វើសេចក្តីសម្រេច (មជ្ឈត្តវិនិច្ឆ័យ) ដើម្បីបញ្ចប់វិវាទដោយយុត្តិធម៌ និងអព្យាក្រឹត។ មានសិទ្ធិ មានសិទ្ធិស្វែងរកការពិត និងសួរដេញដោលភាគីវិវាទ និងសិទ្ធិចេញសេចក្តីសម្រេចដែលមានតម្លៃគតិយុត្តិ (ភាគីត្រូវតែអនុវត្តតាម)។ ទទួលបានប្រាក់កម្រៃសម្រាប់ការបំពេញការងារតាមកិច្ចសន្យា។

**ខ. ព្រះរាជអាជ្ញា (អាជ្ញាកណ្តាលអមតុលាការ)៖** ក្នុងនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាដើរតួជាតំណាងអយ្យការ ដែលមានភារកិច្ចការពារផលប្រយោជន៍សាធារណៈ។ មានតួនាទី ការចោទប្រកាន់ បើកការស៊ើបអង្កេត និងចោទប្រកាន់បុគ្គលដែលប្រព្រឹត្តបទល្មើស។ការអនុវត្តច្បាប់ តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវក្នុងសង្គម។អមតុលាការ ចូលរួមក្នុងសវនាការដើម្បីសន្និដ្ឋានទោសលើ

---

[4] សៀវភៅរបស់មូលនិធិអាស៊ីស្តីពីដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ ដ.ឯ.ម ទំព័រ៨។

[5] ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឆ្នាំ២០១៩ ទំព័រ២។

ជនជាប់ចោទ។ មានសិទ្ធិមានសិទ្ធិចេញដីកាបញ្ជាឱ្យចូលខ្លួន ឬដីកាបង្គាប់ឱ្យនាំខ្លួន។ មានសិទ្ធិតំណាងឱ្យរដ្ឋក្នុងការប្តឹងផ្តល់ក្នុងរឿងក្តីព្រហ្មទណ្ឌ។

## ២.៤. ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅតុលាការ

ក្របខណ្ឌច្បាប់សម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា ត្រូវបានពង្រឹងយ៉ាងខ្លាំងតាមរយៈការបង្កើត អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.) ក្នុងឆ្នាំ ២០២៣ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពឆាប់រហ័សក្នុងការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ។

**ក. លិខិតបទដ្ឋានគតិយុត្តថ្មី៖** ព្រះរាជក្រឹត្យស្តីពីការបង្កើត អ.ដ.ក. ជាមូលដ្ឋានគ្រឹះក្នុងការបង្កើតយន្តការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការដែលផ្តល់ទម្ងន់ផ្លូវច្បាប់ដល់កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ អនុក្រឹត្យ និងសេចក្តីសម្រេច៖ រួមមានអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ និងសេចក្តីសម្រេចស្តីពីលក្ខន្តិកៈមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។

**ខ. ក្របខណ្ឌច្បាប់តាមវិស័យ៖** វិវាទពាណិជ្ជកម្ម៖ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធានរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (NCAC)។ វិវាទការងារ ការដោះស្រាយតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាយន្តការឯករាជ្យសម្រាប់វិវាទការងាររួម។ វិវាទរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានចែងពីវិធានគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងការសម្រុះសម្រួលវិវាទផងដែរ។

**គ. យន្តការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ-សង្កាត់៖** មានតួនាទីក្នុងការសម្រុះសម្រួលវិវាទមូលដ្ឋាន (ដូចជាវិវាទដីធ្លីកម្រិតស្រាល ឬវិវាទគ្រួសារ) តាមរយៈគណៈកម្មការសម្រុះសម្រួលវិវាទឃុំ-សង្កាត់។

អត្ថប្រយោជន៍នៃយន្តការនេះ មានភាពឆាប់រហ័ស និងចំណាយតិច កាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ និងសន្សំសំចៃពេលវេលាសម្រាប់ភាគីវិវាទ។ រក្សាទំនាក់ទំនងការដោះស្រាយតាមរយៈការសម្រុះសម្រួលជួយរក្សាចំណងមិត្តភាពឬទំនាក់ទំនងអាជីវកម្មរវាងភាគីទាំងសងខាង។

## ២.៤.១. ច្បាប់ស្តីពីអាជ្ញាកណ្តាលពាណិជ្ជកម្ម

ច្បាប់ដែលកំណត់អំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងវិស័យពាណិជ្ជកម្មនៅកម្ពុជា គឺ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។ ខ្លឹមសារសំខាន់ៗនៃច្បាប់នេះរួមមានសម្របសម្រួលការដោះស្រាយវិវាទពាណិជ្ជកម្មដោយសន្តិវិធី និងឆាប់រហ័ស តាមរយៈភាគីទីបី (មជ្ឈត្តករ) ដែលមានលក្ខណៈឯករាជ្យ និងមិនលំអៀង។

# ជំពូកទី៣ នីតិវិធីនិងដំណាក់កាលនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ

## ៣.១. នីតិវិធីនៃការដោះស្រាយវិវាទក្រៅតុលាការ

នៅកម្ពុជាដំណើរការមជ្ឈត្តការពាណិជ្ជកម្មអាចប្រព្រឹត្តទៅតាមការព្រមព្រៀងរបស់គូភាគីទាក់ទងនឹងនីតិវិធីដែលត្រូវអនុវត្តក្នុងការដោះស្រាយវិវាទ។ ប្រសិនបើគូភាគីមិនបានកំណត់នីតិវិធីជាមុនទេ វេទិកាមជ្ឈត្តការអាចរៀបចំដំណើរការតាមវិធីដែលខ្លួនយល់ថាសមស្រប។ នៅក្នុងករណីដែលគូភាគីជ្រើសរើសមជ្ឈត្តការដែលមានការគ្រប់គ្រង ដំណើរការនោះនឹងត្រូវគ្រប់គ្រងដោយ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) ហើយត្រូវអនុវត្តស្របតាម ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធានរបស់ ម.ជ.ម.។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានកំណត់បទប្បញ្ញត្តិសំខាន់ៗទាក់ទងនឹងដំណើរការមជ្ឈត្តការដូចជា កិច្ចព្រមព្រៀងមជ្ឈត្តការ សមាសភាព និងយុត្តាធិការរបស់វេទិកាមជ្ឈត្តការ ការគ្រប់គ្រងដំណើរការមជ្ឈត្តការ ការទទួលស្គាល់ និងការអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តការ។ ទោះជាយ៉ាងណា គូភាគីក៏អាចជ្រើសរើសវិធានមជ្ឈត្តការផ្សេងៗបាន ដូចជាវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរីជាដើម។ គួរបញ្ជាក់ផងដែរថា ច្បាប់នេះបានកំណត់កម្រិតនៃការអន្តរាគមន៍របស់តុលាការក្នុងដំណើរការមជ្ឈត្តការ ដើម្បីធានាឱ្យមានឯករាជ្យភាពនៃមជ្ឈត្តការ។ ទោះជាយ៉ាងណាតុលាការនៅតែមានតួនាទីត្រួតពិនិត្យក្នុងករណីខ្លះៗ ដូចជា ការតែងតាំងមជ្ឈត្តករ ការជំទាស់មជ្ឈត្តករ ឬការអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តការ។

### ៣.១.១. ការដាក់ពាក្យស្នើសុំដោះស្រាយវិវាទ

ដំណើរការមជ្ឈត្តការចាប់ផ្តើមនៅពេលដែលភាគីមួយដាក់ សេចក្តីជូនដំណឹងអំពីមជ្ឈត្តការជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត។ ភាគីដែលផ្តួចផ្តើមហៅថា ភាគីប្តឹងទាមទារ ចំណែកភាគីដែលទទួលសំណើហៅថា ភាគីឆ្លើយតប។ សេចក្តីជូនដំណឹងនេះត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. និងត្រូវភ្ជាប់ព័ត៌មានសំខាន់ៗដូចជា៖

- ព័ត៌មានអំពីឈ្មោះ និងអាសយដ្ឋានរបស់គូភាគី
- សេចក្តីយោងនៃខចែងមជ្ឈត្តការ ឬកិច្ចសន្យាដែលពាក់ព័ន្ធ
- ការពិពណ៌នាអំពីវិវាទ និងការទាមទាររបស់ភាគីប្តឹង
- ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬដែលស្នើសុំ

- សំណើបន្ថែមទាក់ទងនឹងភាសា និងច្បាប់ដែលត្រូវអនុវត្ត។

សេចក្ដីជូនដំណឹងនេះត្រូវភ្ជាប់ជាមួយនឹងការបង់ថ្លៃសេវាចុះបញ្ជី ហើយដំណើរការមជ្ឈត្តការនឹងចាប់ផ្ដើមនៅពេលដែលភាគីឆ្លើយតបទទួលបានការជូនដំណឹងពេញលេញ។

### ៣.១.២. ការជ្រើសរើសអ្នកសម្រុះសម្រួល ឬអាជ្ញាកណ្ដាល

បន្ទាប់ពីដាក់បណ្ដឹង ភាគីវិវាទត្រូវធ្វើការជ្រើសរើសវេទិកាមជ្ឈត្តកម្ម និងចំនួនមជ្ឈត្តករ។ ជាទូទៅ វេទិកាមជ្ឈត្តកម្មត្រូវមាន មជ្ឈត្តករ ៣ នាក់ លើកលែងតែភាគីព្រមព្រៀងផ្សេង។ ភាគីនីមួយៗអាចតែងតាំងមជ្ឈត្តករម្នាក់ ហើយមជ្ឈត្តករទាំងពីរនឹងជ្រើសរើសមជ្ឈត្តករទីបី។ ប្រសិនបើមិនអាចធ្វើការតែងតាំងបានក្នុងរយៈពេលកំណត់ តុលាការ ឬមជ្ឈមណ្ឌលមជ្ឈត្តកម្មអាចធ្វើការតែងតាំងជំនួស។

មុនពេលទទួលតំណែង មជ្ឈត្តករត្រូវបង្ហាញព័ត៌មានណាមួយដែលអាចប៉ះពាល់ដល់ អព្យាក្រឹតភាព និងឯករាជ្យភាព របស់ខ្លួន។ ប្រសិនបើភាគីណាមួយមានការសង្ស័យ អាចដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ហើយវេទិកាមជ្ឈត្តកម្មនឹងពិនិត្យ និងសម្រេចលើការជំទាស់នោះ។

## ៣.២. ដំណាក់កាលនៃការដោះស្រាយវិវាទ

ដំណើរការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ អាចបែងចែកជា ៣ ដំណាក់កាលសំខាន់ៗ៖

**ក. ដំណាក់កាលត្រៀមលក្ខណៈ និងការដាក់ពាក្យបណ្ដឹង៖** ភាគីត្រូវពិនិត្យកិច្ចសន្យាពាណិជ្ជកម្មថាមានខចែងស្ដីពីការដោះស្រាយវិវាទឬអត់ ហើយបន្ទាប់មកភាគីដើមបណ្ដឹងដាក់ពាក្យស្នើសុំទៅស្ថាប័នដោះស្រាយវិវាទដោយភ្ជាប់ភស្តុតាង និងបង់កម្រៃសេវា។

**ខ. ដំណាក់កាលជ្រើសរើសអ្នកជំនាញ និងការសម្រុះសម្រួល៖** ភាគីអាចជ្រើសរើសមជ្ឈត្តករ ឬអ្នកសន្ទានការីដែលមានជំនាញ និងអព្យាក្រឹតភាព។ ក្នុងដំណាក់កាលនេះ ភាគីអាចព្យាយាមសម្រុះសម្រួលតាមរយៈការចរចា។ ប្រសិនបើសម្រុះសម្រួលជោគជ័យ ភាគីនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសះជា។

**គ. ដំណាក់កាលចេញសេចក្ដីសម្រេច៖** ប្រសិនបើការសម្រុះសម្រួលមិនជោគជ័យ វេទិកាមជ្ឈត្តកម្មនឹងបើកសវនាការ និងពិនិត្យភស្តុតាង។ បន្ទាប់ពីសវនាការ មជ្ឈត្តករនឹងចេញសេចក្ដីសម្រេចដែលមានតម្លៃបង្គាប់ឱ្យអនុវត្ត។ ប្រសិនបើភាគីមិនអនុវត្តតាម ភាគីឈ្នះអាចស្នើសុំតុលាការឱ្យបង្ខំអនុវត្តតាមច្បាប់។

## ៣.៣. កត្តាដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទ

ប្រសិទ្ធភាពនៃការដោះស្រាយវិវាទមិនអាស្រ័យតែវិធីសាស្ត្រដែលបានជ្រើសរើសប៉ុណ្ណោះទេ ប៉ុន្តែអាស្រ័យផងដែរលើកត្តាជាច្រើនដែលអាចជួយឬរារាំងដល់ដំណើរការនេះ។ ជាទូទៅកត្តាសំខាន់ៗដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ រួមមានការសហការរបស់ភាគីដែលពាក់ព័ន្ធ បទពិសោធន៍ និងសមត្ថភាពរបស់អាជ្ញាកណ្តាល ឬអ្នកសម្របសម្រួល ក៏ដូចជាកត្តាច្បាប់ និងស្ថានភាពសេដ្ឋកិច្ច ឬទីផ្សារ។ កត្តាទាំងនេះមានតួនាទីសំខាន់ក្នុងការកំណត់ថាតើការដោះស្រាយវិវាទអាចសម្រេចបានដោយសន្តិវិធី និងមានប្រសិទ្ធភាពកម្រិតណា។

### ៣.៣.១. ការសហការរបស់ភាគី

ការសហការរបស់ភាគីដែលពាក់ព័ន្ធ គឺជាកត្តាសំខាន់បំផុតមួយដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទ។ ក្នុងដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីទាំងពីរត្រូវមានឆន្ទៈក្នុងការចូលរួមពិភាក្សា បង្ហាញទស្សនៈរបស់ខ្លួន និងស្វែងរកដំណោះស្រាយដែលអាចទទួលយកបានដោយគ្នាទៅវិញទៅមក។ ការសហការដ៏ល្អអាចជួយឱ្យដំណើរការដោះស្រាយវិវាទមានភាពរលូន និងអាចបញ្ចប់បានក្នុងរយៈពេលខ្លី។

### ៣.៣.២. បទពិសោធន៍របស់អាជ្ញាកណ្តាល

បទពិសោធន៍ និងជំនាញរបស់អាជ្ញាកណ្តាល ឬអ្នកសម្របសម្រួល មានឥទ្ធិពលយ៉ាងខ្លាំងលើលទ្ធផលនៃការដោះស្រាយវិវាទ។ អាជ្ញាកណ្តាលដែលមានចំណេះដឹងផ្នែកច្បាប់មានបទពិសោធន៍ និងមានសមត្ថភាពក្នុងការវិភាគបញ្ហា អាចជួយណែនាំភាគីឱ្យរកដំណោះស្រាយបានយ៉ាងត្រឹមត្រូវ និងយុត្តិធម៌។ បន្ថែមពីនេះ ការសម្រេចចិត្តរបស់អាជ្ញាកណ្តាលដែលមានជំនាញក៏អាចបង្កើនទំនុកចិត្តរបស់ភាគីទាំងពីរផងដែរ។

### ៣.៣.៣. កត្តាច្បាប់និងស្ថានភាពទីផ្សារ

កត្តាច្បាប់ និងស្ថានភាពទីផ្សារ ក៏ជាកត្តាសំខាន់ដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទ។ ប្រសិនបើមានច្បាប់ និងបទប្បញ្ញត្តិច្បាស់លាស់ វាអាចជួយឱ្យដំណើរការដោះស្រាយវិវាទមានទិសដៅច្បាស់ និងមានយុត្តិធម៌។ លើសពីនេះ ស្ថានភាពទីផ្សារ ដូចជាការប្រកួតប្រជែង ស្ថានភាពសេដ្ឋកិច្ច ឬទំនាក់ទំនងពាណិជ្ជកម្ម ក៏អាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគីក្នុងការទទួលយកដំណោះស្រាយផងដែរ។

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាអំពីការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ អាចឃើញថាវាជាវិធីសាស្ត្រសំខាន់មួយដែលជួយដោះស្រាយវិវាទរវាងភាគីដែលពាក់ព័ន្ធបានយ៉ាងមានប្រសិទ្ធភាព។ វិធីសាស្ត្រនេះអនុញ្ញាតឱ្យភាគីអាចស្វែងរកដំណោះស្រាយដោយសន្តិវិធី ដោយមិនចាំបាច់បញ្ជូនករណីទៅតុលាការ ដែលជារឿយៗអាចចំណាយពេលវេលាយូរ និងចំណាយថវិកាច្រើន។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានវិធីសាស្ត្រផ្សេងៗដូចជា ការចរចា ការសម្របសម្រួល និងអាជ្ញាកណ្តាល។ វិធីសាស្ត្រទាំងនេះអាចជួយឱ្យភាគីពាក់ព័ន្ធរកដំណោះស្រាយដែលទាំងពីរភាគីអាចទទួលយកបាន ហើយក៏អាចជួយរក្សាទំនាក់ទំនងល្អក្នុងវិស័យពាណិជ្ជកម្មផងដែរ។ លើសពីនេះ វាក៏ជួយកាត់បន្ថយបន្ទុកការងាររបស់តុលាការ និងបង្កើនប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទ។

យ៉ាងណាក៏ដោយ ប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ អាស្រ័យលើកត្តាចម្បងជាច្រើន ដូចជា ការសហការរបស់ភាគី បទពិសោធន៍ និងសមត្ថភាពរបស់អាជ្ញាកណ្តាល ឬអ្នកសម្របសម្រួល និងកត្តាច្បាប់ពាក់ព័ន្ធ។ ប្រសិនបើកត្តាទាំងនេះមានភាពអំណោយផល វាអាចធ្វើឱ្យដំណើរការដោះស្រាយវិវាទប្រព្រឹត្តទៅបានយ៉ាងរលូន និងទទួលបានលទ្ធផលល្អសម្រាប់ភាគីទាំងអស់។

ដោយសារហេតុនេះ ការលើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់វិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងការរក្សាបរិយាកាសធុរកិច្ចដែលមានស្ថិរភាព។ វិធីសាស្ត្រនេះអាចជួយឱ្យភាគីដែលមានវិវាទរកដំណោះស្រាយបានយ៉ាងមានប្រសិទ្ធភាព និងរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសង្គម។

## ឯកសារយោង


- ច្បាប់ស្តីពីអាជ្ញាកណ្តាលពាណិជ្ជកម្មភ្នំពេញព្រះរាជាណាចក្រកម្ពុជា២០០៦។
- មជ្ឈមណ្ឌលជាតិអាជ្ញាកណ្តាលពាណិជ្ជកម្ម២០១៧។ វិធានអាជ្ញាកណ្តាលរបស់ NCAC។ ភ្នំពេញ។
- ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រសួងយុត្តិធម៌ភ្នំពេញ។
- សៀវភៅមេរៀន នីតិពាណិជ្ជកម្ម និងការដោះស្រាយវិវាទពាណិជ្ជកម្ម។
- មជ្ឈមណ្ឌលបណ្តុះបណ្តាលច្បាប់ និងយុត្តិធម៌ ឯកសារបណ្តុះបណ្តាលអំពីការសម្របសម្រួល និងអាជ្ញាកណ្តាល។
- សៀវភៅរបស់មូលនិធិអាស៊ីស្តីពីដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការបោះពុម្ពឆ្នាំ ២០០១។
- សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់របស់USAID/CAMBODIA, "ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា" មេធាវី អ៊ឹម អូស្មើរមីល្លីវ បោះពុម្ពឆ្នាំ២០១០។
- និក្ខេបបទថ្នាក់អនុបណ្ឌិត "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" កៅ សីហា ឆ្នាំ២០១០
- ក្រសួងព័ត៌មាន https://economy.ams.com.kh/real-estate/news/learn-about-the-benefits-of-out-of-court-dispute-resolution/